# របាយការណ៍ប្រចាំខែតុលា ឆ្នាំ ២០១៤ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ

នៅក្នុងខែតុលា ឆ្នាំ ២០១៤ មន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ បានបំពេញភារកិច្ចសម្រេចលទ្ធផលដូចខាងក្រោម÷

1. **<u>ស្ថានភាពមន្ត្រីរាជការ</u>**÷

ស្ថានភាពមន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ សរុបចំនួន ៣១ នាក់ ស្ត្រី ០៤ នាក់ និងដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអនុប្រធានមន្ទីរ ០២ រូប ។

2. **<u>សកម្មភាពថ្នាក់ដឹកនាំមន្ទីរ</u>** ÷

- ចូលរួមកិច្ចប្រជុំប្រមូលព័ត៌មានទិន្នន័យសម្រាប់ចងក្រង GDP សាកល្បងរបស់ខេត្តក្រចេះថ្ងៃទី២៩/០៩/២០១៤ នៅសណ្ឋាគារ ហ៊ារ ប៊ុន្នី
- ចូលរួមវេទិកាសាធារណៈជួបជាមួយប្រជាពលរដ្ឋនៅភូមិសំបូរស្រុកសំបូរ ថ្ងៃទី៣/១០/២០១៤
- ចូលរួមប្រជុំការងារវាយតម្លៃទីក្រុងស្អាតខេត្តក្រចេះ ថ្ងៃទី០៦/១០/២០១៤ នៅសាលាប្រជុំសាលាខេត្ត
- ចូលរួមក្នុងទិវាមនុស្សចាស់កម្ពុជា ទិវាមនុស្សចាស់អន្តរជាតិ ១ តុលា ឆ្នាំ ២០១៤ នៅថ្ងៃទី០៧/១០/២០១៤ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំពិភាក្សា និងពិនិត្យលើទិន្នន័យដីសហគមន៍ជនជាតិដើមភាគតិច ដែលវាស់វែងរួច នៅភូមិពន្ធដារ និងភូមិអូរកក់ ឃុំអូរគ្រៀង ថ្ងៃទី០៨/១០/២០១៤
- ចូលរួមប្រជុំបូកសរុបលទ្ធផលការងារលើគ្រប់វិស័យ ប្រចាំត្រីមាសទី ៣ ឆ្នាំ ២០១៤ របស់គណៈកម្មការនាយកមូលនិធិសមធមិខេត្តក្រចេះ ថ្ងៃទី០៩/១០/២០១៤ នៅមន្ទីរពេទ្យបង្អែកឆ្លូង និងថ្ងៃទី១០/១០/២០១៤ នៅមន្ទីរពេទ្យបង្អែកខេត្ត
- ចូលរួមប្រជុំបូកសរុបលទ្ធផលការងារលើគ្រប់វិស័យ ប្រចាំត្រីមាសទី ៣ ឆ្នាំ ២០១៤ ថ្ងៃទី ១០/១០/២០១៤ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំប្រចាំសប្តាស់របស់ក្រសួងអភិវឌ្ឍន៍ជនបទ ថ្ងៃទី ១៣/១០/២០១៤
- ចូលរួមប្រជុំត្រៀមរៀបចំពិធីគោរពវិញ្ញាណក្ខន្ធ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះបរមរតនៈកោដ្ឋ** សម្រាប់ខួប ២ ឆ្នាំ និងព្រះរាជពិធីបុណ្យអុំទូកអកអំបុកសំពះព្រះ ខែឆ្នាំ២០១៤ នៅថ្ងៃទី០៨/១០/២០១៤ នៅសាលប្រជុំសាលាខេត្ត និងគោរពព្រះវិញ្ញាណក្ខន្ធ ថ្ងៃទី១៤/១០/២០១៤ នៅសាលមហោស្រពខេត្ត
- ចូលរួមសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការមជ្ឈមណ្ឌល អភិវឌ្ឍន៍ស្ត្រីខេត្តក្រចេះ ថ្ងៃទី១៤/១០/២០១៤ នៅមជ្ឈមណ្ឌល អូរឫស្សី ២ សង្កាត់អូរឫស្សី
- ចូលរួមចែកអំណោយ ដល់ប្រជាពលរដ្ឋរងគ្រោះ ដោយសារទឹកជំនន់ទន្លេមេគង្គ ថ្ងៃទី១៥/១០/២០១៤ នៅស្រុកឆ្លូង
- ចូលរួមប្រជុំសាមញ្ញលើកទី៥ អាណត្តិទី២ របស់ក្រុមប្រឹក្សាខេត្ត ថ្ងៃទី១៦/១០/២០១៤ នៅសាលប្រជុំរបស់ក្រុមប្រឹក្សាខេត្ត

- ចូលរួមប្រគល់សញ្ញាបត្រ ដល់សិស្ស និស្សិត UME ថ្ងៃទី១៧/១០/២០១៤ នៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត
- ចូលរួមប្រជុំសាមញ្ញរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ថ្ងៃទី២០/១០/២០១៤ នៅសាលប្រជុំរបស់ក្រុមប្រឹក្សាខេត្ត
- ចូលរួមប្រជុំបណ្តាញយេនឌ័រថ្នាក់ខេត្ត ថ្ងៃទី២១/១០/២០១៤ មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ខេត្តក្រចេះ
- ចូលរួមប្រជុំពិភាក្សាលើការងារ ធ្វើសមាហរណកម្មក្របខ័ណ្ឌមន្ត្រីរាជការ ការបញ្ចូលកាំប្រាក់បៀវត្សមន្ត្រីរាជការ និងបើកប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ នៅថ្ងៃទី ២១/១០/២០១៤ និងប្រជុំពិនិត្យពិភាក្សាសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សហគមន៍ នៅថ្ងៃទី ២៤/១០/២០១៤ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។

3. ***សកម្មភាពតាមការិយាល័យ***÷

3.1. ***ការិយាល័យរដ្ឋបាល និងបុគ្គលិក***÷

ក. ផ្នែកការងារលិខិតចូល ÷ សរុបចំនួន ៨៣ លេខ ក្នុងនោះមានៈ

- លិខិតរបស់រាជរដ្ឋាភិបាល ចំនួន ០៦ លេខ
- លិខិតរបស់ក្រសួងសាមី ចំនួន ០៩ លេខ
- លិខិតក្រសួងនានា ចំនួន ២០លេខ
- លិខិតផ្សេងៗក្នុងខេត្ត ចំនួន ៤៨ លេខ

ខ. ផ្នែកការងារលិខិតចេញ÷ សរុបចំនួន ៤៣ លេខ ក្នុងនោះមានៈ

- លិខិតទៅនាយកដ្ឋាន និងក្រសួងសាមី ចំនួន ១៩ លេខ
- លិខិតផ្សេងៗទូទៅ ក្នុងខេត្ត ចំនួន ២៤ លេខ

គ. ផ្នែកការងារលិខិតបញ្ជាបេសកកម្ម÷ សរុបចំនួន ២៩ លេខ

- ធ្វើសំណើសុំលិខិតបញ្ជាបេសកកម្មលោកប្រធានមន្ទីរ ពី **ឯកឧត្តមអភិបាលខេត្ត** ចំនួន០៤លេខ
- ចេញលិខិតបញ្ជាបេសកកម្មជូនមន្ត្រីចំនួន ២៥ លេខ

ឃ. ផ្នែកបញ្ជីវត្តមាន÷ ពិនិត្យការចុះបញ្ជីវត្តមានជាប្រចាំថ្ងៃ ។

3.2. ***ការិយាល័យផ្លូវលំជនបទ***÷

3.2.1. លទ្ធផលការងារ÷

- ការងារជួសជុលផ្លូវថែទាំជាលក្ខណៈខួប ភូមិអូរព្រះ ទៅភូមិខ្សាច់លាវ ឃុំអូរគ្រៀង ស្រុកសំបូរ ប្រវែង ១០.០០០ ម៉ែត្រ សម្រេចលទ្ធផលបាន ៨.០០០ ម៉ែត្រ ។
- ការងារជួសជុលថែទាំផ្លូវ ភូមិឈ្នៃទៅភូមិស្រែទ្រៀក ឃុំឆ្លូង និងឃុំដីវីផុង ស្រុកឆ្លូង ប្រវែង ១៩.២០០ ម៉ែត្រ លទ្ធផលសម្រេចបាន ១០.០០០ ម៉ែត្រ ។

3.2.2. <u>សកម្មភាពការិយាល័យ</u>÷

- ចុះទៅពិនិត្យការងារថែទាំផ្លូវជាលក្ខណៈប្រចាំ ផ្លូវបន្ទាយទៅបុស្សផល ឃុំគោលាប់ ប្រវែង ១០.៤០០ ម៉ែត្រ និង ផ្លូវចង្ក្រង់ទៅថ្មគ្រែ ឃុំចង្ក្រង់ ក្នុងស្រុកចិត្របុរី ប្រវែង ៨.០០០ ម៉ែត្រ បានចំនួន ៣ លើក ។
- ចុះទៅពិនិត្យការងារជួសជុលផ្លូវថែទាំជាលក្ខណៈខួប ភូមិអូរព្រះ ទៅ ភូមិខ្សាច់លាវ ឃុំអូរគ្រៀង ស្រុកសំបូរ ប្រវែង ១០.០០០ ម៉ែត្រ បានចំនួន ៤ លើក ។
- ចុះទៅពិនិត្យការងារជួសជុលថែទាំផ្លូវ ភូមិឈ្ងែ ទៅ ភូមិស្រែទ្រៀក ឃុំឆ្លូង និងឃុំដំរីផុង ស្រុកឆ្លូង ប្រវែង១៩.២០០ បានចំនួន ៤ លើក ។

## 3.3. <u>**ការិយាល័យផ្គត់ផ្គង់ទឹកជនបទ**</u>÷

- ចុះជួសជុលអណ្តូងស្នប់បានចំនួន ៥ អណ្តូង÷
  - ស្រុកសំបូរ ចំនួន ០២ អណ្តូង ស្ថិតនៅឃុំសណ្តាន់ គឺភូមិសង្គម ០១អណ្តូង និងភូមិថ្មី ០១អណ្តូង
  - ក្រុងក្រចេះចំនួន ០៣ អណ្តូង ស្ថិតនៅសង្កាត់កោះទ្រង់ ភូមិក្បាលកោះ
- សាងសង់អណ្តូងស្នប់ថ្មីបានចំនួន ០៤ អណ្តូង នៅស្រុកចិត្របុរី (ឃុំសំបុក ភូមិសំបុក ០២ អណ្តូង) និងឃុំចង្ក្រង់ ០២ អណ្តូង (ភូមិកសាង ០១ អណ្តូង និង ភូមិចង្ក្រង់ ០១ អណ្តូង) លទ្ធផលទទួលបាន ១០០% ។

## 3.4. <u>**ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ**</u>÷

- ចូលរួមប្រជុំក្រុមការងារអង្កេតព័ត៌មានសេដ្ឋកិច្ច និងសង្គមនៅការិយាល័យអង្គការ Oxfam ដែលសមាសភាពចូលរួមមានអង្គការ Kafdoc, Oxfam, PYD មន្ទីរកិច្ចការនារី មន្ទីរកសិកម្មខេត្ត សហគមន៍សន្សំប្រាក់ ឃុំវឌ្ឍនៈ ឃុំព្រែកប្រសព្វ ឃុំកោះច្រែង និងឃុំបុសលាវ មានអ្នកចូលរួមចំនួន ១៥ នាក់ ស្ត្រី៥ នាក់
- ចូលរួមប្រជុំឥណទានលុយដល់ប្រជាជន ១៧ នាក់ ស្ត្រី ៧ នាក់ ឃុំព្រែកប្រសព្វ ចំនួន ២៤.៦០០.០០០ រៀល សំរាប់ធ្វើស្រែ ចិញ្ចឹមមាន់ ចិញ្ចឹមជ្រូក និងដាំដំឡូង ។

## 3.5. <u>**ការិយាល័យអភិវឌ្ឍន៍សហគមន៍**</u>÷

- ចុះបណ្តុះបណ្តាល គ.អ.ភ ប្រជាពលរដ្ឋ ស្តីពីការត្រៀមបង្ការ និងកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ចំនួន ០៣ វគ្គ ក្នុងស្រុកចិត្របុរី ឃុំបុសលាវ ស្រុកឆ្លូង ឃុំព្រែកសាម៉ាន់, ២ ស្រុក ស្មើ ០២ ឃុំ ស្មើ ០៦ ភូមិ អ្នកចូលរួមចំនួន ១០៥ នាក់ ស្ត្រី ៣៧ នាក់
- ផ្តល់ពូជក្រូចថ្លុងផ្អែម ចំនួន ១៣០ ដើម នៅភូមិតាងួន ឃុំវឌ្ឍនៈ ស្រុកសំបូរ របស់គម្រោងអភិវឌ្ឍន៍ភូមិ
- ចុះបណ្តុះបណ្តាល គ.អ.ភ នៅភូមិសំបូរសែនជ័យ ឃុំស្វាយជ្រះ ស្រុកស្នួល ស្តីពីតួនាទី និងភារកិច្ចរបស់ គ.អ.ភ

- ចុះត្រួតពិនិត្យ និងតាមដានសមាសភាព គ.អ.ភ នៅឃុំឃ្សឹម ស្រុកស្នួល
- សហការជាមួយអង្គការ ឆាលហ្វានកម្ពុជាប្រចាំខេត្តក្រចេះ រៀបចំឯកសារសម្រាប់បណ្តុះបណ្តាល ដើម្បីរៀបចំ គ.អ.ភ នៅស្រុកឆ្លូង
- ចុះបណ្តុះបណ្តាល គ.អ.ភ ស្តីពីគោលគំនិតនៃការអភិវឌ្ឍសហគមន៍ ក្រោមកិច្ចសហការរវាងមន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ និងអង្គការឆាលហ្វានកម្ពុជាប្រចាំខេត្តក្រចេះ បាន ចំនួន ៤ វគ្គ ស្មើនឹង ៣ឃុំ ស្មើនឹង ១៤ភូមិ និងមាន គ.អ.ភ ចូលរួមចំនួន ១១០ នាក់ ក្នុងនោះ ស្ត្រីមានចំនួន ៦៨ នាក់ ។

3.6. **ការិយាល័យជនជាតិដើមភាគតិច**÷

- ចូលរួមសម្របសម្រួលកិច្ចប្រជុំផ្សព្វផ្សាយ អំពីសារៈប្រយោជន៍នៃការរៀបចំសហគមន៍ជន ជាតិដើមភាគតិចនៅឃុំអូរគ្រៀង និងឃុំបឹងចារ ដែលមានអ្នកចូលរួម២១៨នាក់ ស្ត្រី១២៥នាក់ក្នុងនោះ÷
    - ឃុំអូរគ្រៀង មានអ្នកចូលរួម ៦៩ នាក់ស្ត្រី ៣៦ នាក់
    - ឃុំបឹងចារ មានអ្នកចូលរួម ១៤៩ នាក់ ស្ត្រី ៨៩ នាក់ ។

3.7. **ការិយាល័យថែទាំសុខភាពជនបទ**÷

- ចុះផ្សព្វផ្សាយ និងបំផុស ឲ្យប្រជាជនស្ម័គ្រចិត្តសាងសង់បង្គន់ដោយខ្លួនឯង បានចំនួន ៧៨ បង្គន់ ក្នុងនោះមាន:
    - ស្រុកឆ្លូង ៦៣ បង្គន់
    - ស្រុកចិត្របុរី ១៥ បង្គន់ ។

3.8. **ការងារបណ្តុះបណ្តាលមន្ត្រីរាជការ**÷

- លោក ធន សារី អនុប្រធានមន្ទីរ លោក អ៊ុត អុល ប្រធានការិយាល័យផែនការ និងស្ថិតិ លោក សន ធី ប្រធានការិយាល័យ គណនេយ្យ-ហិរញ្ញវត្ថុ និង ធុន បូនិត (ស) មន្ត្រីការិយាគណនេយ្យ-ហិរញ្ញវត្ថុ បានចូលរួមសិក្ខាសាលាស្តីពីការពង្រឹង សមត្ថភាពអនុវត្តថវិកាកម្មវិធី កាលពីថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០១៤ នៅខេត្តព្រះសីហនុ ក្រោមការឧបត្ថម្ភដោយ ក្រសួងអភិវឌ្ឍន៍ជនបទ ។
- លោក ម៉ៅ សុខជា អនុប្រធានមន្ទីរ បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់តំបន់ ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការជាតិអភិវឌ្ឍន៍កុមារ កាលពីថ្ងៃទី ២០ ខែតុលា ឆ្នាំ២០១៤ នៅខេត្តរតនគីរី ក្រោមការឧបត្ថម្ភដោយ ក្រសួងអភិវឌ្ឍន៍ជនបទ ។

4. **ទិសដៅបន្ត**÷

- បន្តការជួសជុលផ្លូវថែទាំជាលក្ខណៈខួប ផ្លូវភូមិអូរព្រះ ទៅ ភូមិខ្សាច់លាវ ប្រវែង ១០.០០០ ម៉ែត្រ ឃុំអូរគ្រៀង ស្រុកសំបូរ ។
- បន្តការជួសជុលថែទាំផ្លូវភូមិឈ្នៃទៅភូមិស្រែទ្រៀក ឃុំឆ្លូង និងឃុំដំរីផុង ស្រុកឆ្លូង ប្រវែង ១៩.២០០ ម៉ែត្រ ។

- ចុះស្រង់ទិន្នន័យផ្លូវតាមប្រព័ន្ធ GPS ក្នុងស្រុកចិត្របុរី និងស្រុកសំបូរ ដើម្បីរៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវ និងផែនទីក្នុងខេត្តក្រចេះ ។
- ចុះស្រង់ព័ត៌មានអណ្តូងស្នប់ដែលខូច ។
- បន្តការងារចុះត្រួតពិនិត្យតាមដាន និងសម្រួលបញ្ជីឈ្មោះគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ នៅតាមភូមិនានា នៅស្រុកស្នួល ខេត្តក្រចេះ និងបន្តវគ្គបណ្តុះបណ្តាលគ.អ.ភ ចំនួន ៦ វគ្គទៀត នៅក្នុងស្រុកឆ្លូង ដែលជាភូមិគោលដៅរបស់អង្គការឆាលហ្វានកម្ពុជា ។
- បណ្តុះបណ្តាល គ.អ.ភ ស្តីពីផែនការសកម្មភាពអភិវឌ្ឍន៍ភូមិ ចំនួន ៦ វគ្គ នៅក្នុងស្រុកសំបូរ ខេត្តក្រចេះ
- ផ្សព្វផ្សាយ និងតាមដានការសាងសង់បង្គន់ចាក់ទឹក នៅឃុំព្រែកសាម៉ាន់ ឃុំកញ្ជរ ស្រុកឆ្លូង, ឃុំសណ្តាន់ ឃុំសំបូរ ស្រុកសំបូរ, ឃុំថ្មគ្រែ ឃុំគោលាប់ ឃុំបុសលាវ ឃុំសំបុក ស្រុកចិត្របុរី និងឃុំសោប ឃុំព្រែកប្រសព្វ ឃុំចំបក់ ឃុំឬស្សីកែវ ក្នុងស្រុកព្រែកប្រសព្វ ។

**ប្រធានមន្ទីរ**